បច្ចុប្បន្ន ប្រជាពលរដ្ឋនៅតែបន្តរងទុក្ខវេទនាដោយសារការបណ្តេញចេញពីគម្រោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាដូចជាជីវភាពរបស់ប្រជាពលរដ្ឋមានស្ថានភាពយ៉ាប់យឺនជាងមុនពេលអភិវឌ្ឍន៍ ដោយសារការបណ្តាញចេញដោយបង្ខំ ខ្វះការពិគ្រោះយោបល់ជាសាធារណៈឲ្យបានត្រឹមត្រូវមុនការអនុវត្តគម្រោង គ្មានសំណងសមរម្យ និង អយុត្តិធម៌។ ការបណ្តេញដោយបង្ខំ នាំឲ្យឈានទៅដល់ការបាត់បង់ដីធ្លី លំនៅឋាន បាត់បង់មុខរបរប្រចាំថ្ងៃបាត់បង់ទ្រព្យសម្បត្តិ ជាហេតុដែលនាំអោយប៉ះពាល់ផ្លូវចិត្តដល់ក្រុមគ្រួសាររងគ្រោះ និងអនាគតកូន ហើយទីបំផុតនឹងធ្វើឲ្យប្រជាពលរដ្ឋធ្លាក់ក្នុងភាពក្រីក្រ។ ជាងនេះទៀត បញ្ហាតាំងទីលំនៅថ្មី ប្រជាពលរដ្ឋជួបផលលំបាកក្នុង ការទទួលសេវាសាធារណៈដូចជា៖ ការប្រើប្រាស់ទឹកស្អាត ផ្លូវថ្នល់ ផ្សារ សាលារៀន និងមន្ទីរពេទ្យ។ល។ កង្វះការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ទូលំទូលាយជាមួយប្រជាពលរដ្ឋ អំពីគម្រោងផែនការអភិវឌ្ឍន៍ភាគច្រើនរបស់រាជរដ្ឋាភិបាល នាំឲ្យប្រជាពលរដ្ឋក្លាយ ជាជនរងគ្រោះដូចជាការ រំលោភសិទ្ធិមនុស្សជាពិសេសកុមារ និងស្ត្រី និងមិនទទួលបានការដោះស្រាយសមរម្យពីគម្រោងការអភិវឌ្ឍទាំងនោះ។ ម្យ៉ាងទៀតយើងក៏សង្កេតឃើញថា រាល់សកម្មភាពបណ្តេញចេញដោយបង្ខំ អាជ្ញាធរមានសមត្ថកិច្ចតែងតែប្រើអំពើហឹង្សា និងការគំរាមកំហែង ដោយប្រើកំលាំងប្រដាប់អាវុធ រហូតមានការចាប់ខ្លួនបញ្ជូនទៅតុលាការ និងដាក់ឃុំឃាំង កាត់ទោសដោយអយុត្តិធម៌។ អ្នកដែលប្រព្រឹត្តិបទល្មើសមិនត្រូវបាននាំខ្លួនទៅផ្តន្ទាទោសតាមច្បាប់ទេ។ ចំណែកឯការដោះស្រាយសំណងទៀតសោត មិនបានធ្វើឲ្យមានការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋភាគច្រើនទេ ប៉ុន្តែគេត្រូវតែបង្ខំចិត្តចាកចេញពីលំនៅឋានចាស់ទៅកាន់ទីតាំងថ្មីតាមការសម្រេចចិត្តរបស់អាជ្ញាធរ និងក្រុមហ៊ុនវិនិយោគដោយមិនមានសំណងសមរម្យ ហើយអ្នកខ្លះរងនូវការរើសអើងពីអាជ្ញាធរក្នុងពេលដោះស្រាយសំណង ដូចជាអាជ្ញាធរមិនមានការទទួលខុសត្រូវក្នុងការអនុវត្តកាតព្វកិច្ចការពារសិទ្ធិប្រជាពលរដ្ឋដែលជា ហេតុនាំឲ្យប្រជាពលរដ្ឋបាត់បង់ជំនឿទុកចិត្តចំពោះអាជ្ញាធរមានសមត្ថកិច្ច។ ជាមួយនេះគ្នាដែរយន្តការដោះស្រាយ

វិវាទដីធ្លីដែលនៅជាធរមានមិនបានអនុវត្តឲ្យមានប្រសិទ្ធិភាពហើយអាជ្ញាធរតែងតែគេចវេសពីបញ្ហាទាំងនោះ នៅឡើយទេដូចជាប្រជាពលរដ្ឋនៅបន្ត ឡើងមកដាក់ញ្ញាតកាន់តែច្រើន ឡើងដូចជា សហគមន៍ឡពាង កំពង់ឆ្នាំង យុគៀននីរីឡុបមិនគ្រុប កោះកុង សហគមន៍ប្រមេ ព្រះវិហារ ថ្មដាពោធិសាត់ បឹងកក់ បុរីកីឡា ភ្នំពេញ ។ល។

សមិទ្ធផលរបស់រាជរដ្ឋាភិបាល

ទន្ទឹងនឹងបញ្ហាប្រឈមខាងដើម្បីពន្លឿនការដោះស្រាយវិវាទដីធ្លី យើងក៏បានកត់សំគាល់ឃើញថារាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងបង្កើត និង អនុម័តគោលនយោបាយមួយចំនួនដូចជា គោលនយោបាយដីធ្លី"សៀវភៅស" គោលនយោយបាយជាតិលំនៅឋាន គោលនយោបាយវាយតម្លៃថ្លៃអចលនវត្ថុ ។ល។ លើសពីនោះទៀតព្រះរាជាណាចក្រកម្ពុជាបានប្រកាសដាក់ចេញនូវ គោលនយោបាយចាស់ សម្មកភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលនូវកម្មវិធីថ្មីមួយដែល ត្រូវអនុវត្តន៍ដោយក្រុមយុវជនស្ម័គ្រចិត្ត ជាអ្នកជួយចុះវាស់កំណត់ព្រំប្រទល់ដីជូនប្រជាពលរដ្ឋនៅពាតំបន់ ដូចជាដីសម្បទានដីការជេកហូត និងព្រៃសម្បទាន។ គណៈកម្មការរបស់រដ្ឋសភា និងព្រឹទ្ធសភាបានចុះពិនិត្យ និងអញ្ជើញអ្នកព័ន្ធដល់កន្លែងដែលមានវិវាទសម្រាប់ក្នុងរបៀបវារៈដោះស្រាយ។ រាជរដ្ឋាភិបាលក៏បានបើកកិច្ចសហការទូលាយចំពោះសង្គមស៊ីវិលជាជំនួយការក្នុងការដោះស្រាយវិវាទដីធ្លី ឧទាហរណ៍ប្រជុំប្រចាំត្រីមាស និងប្រជុំក្រុមបច្ចេកទេសដីធ្លីជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អនុសាសន៍

សំរាប់រាជរដ្ឋាភិបាល

១. ចុះបញ្ជីដីធ្លីជាប្រព័ន្ធសម្រាប់សហគមន៍ក្រីក្រនៅតាមបណ្តាខេត្ត ក្រុង រាជធានី និងពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋនៅទាំងអស់ទូទាំងប្រទេស។

២. ត្រូវផ្សព្វផ្សាយ និងពិគ្រោះយោបល់ឲ្យបានទូលំទូលាយអំពីគំរោងអភិវឌ្ឍន៍នានាជាមួយប្រជាពលរដ្ឋជាពិសេសសហគមន៍ដែលរស់នៅក្នុងតំបន់រងផលប៉ះពាល់មុននឹង ផ្តល់ការអនុញ្ញាតិឲ្យក្រុមហ៊ុនវិនិយោគ។

៣. រាល់ការអភិវឌ្ឍត្រូវអោយមានផលប្រយោជន៏ដល់ពលរដ្ឋនៅនឹងកន្លែងដែលត្រូវអភិវឌ្ឍន៍។

៤. ធានាប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ ហើយគោរពសិទ្ធិមនុស្ស និងបញ្ឈប់ប្រើប្រាស់ប្រព័ន្ធតុលាការមកគាបសង្កត់មកលើប្រជាពលរដ្ឋដែលទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋានរបស់ខ្លួន។

៥. បញ្ឈប់ការបណ្តេញចេញដោយបង្ខំ ប៉ុន្តែត្រូវធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង។

៦. ដោះលែងជាបន្ទាន់ប្រជាពលរដ្ឋដែលតវ៉ាទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានចេញពីពន្ធនាគារ។

៧. បញ្ឈប់ការរារាំងសកម្មភាពអហឹង្សារបស់ប្រជាពលរដ្ឋរងគ្រោះ ឧទាហរណ៍ ការដាក់ញត្តិ សំណូមពរផ្សេងៗទៀត។

៨. បញ្ឈប់ការចោទប្រកាន់អង្គការសង្គមស៊ីវិលថាជាអ្នកញុះញង់នៅពីក្រោយប្រជាពលរដ្ឋ

សំរាប់ម្ចាស់ជំនួយ

១. ជួយបន្តការគាំទ្រពល់គម្រោង និងសកម្មភាពដោះស្រាយទៅលើបញ្ហាទំនាស់ដីធ្លី និងលំនៅឋាន ប្រកបដោយប្រសិទ្ធភាព។

២. បន្តសហការជាមួយរាជរដ្ឋាភិបាលក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងជម្រុញឲ្យរាជរដ្ឋាភិបាល បន្តដោះស្រាយសំណូមពរ និងអនុសាសន៍ផ្សេងៗរបស់ប្រជាពលរដ្ឋរងគ្រោះ។

៥)សិទ្ធិទទួលព័ត៌មាន

បញ្ហាប្រឈម

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជានៅមិនទាន់មានវប្បធម៌បើកចំហរព័ត៌មានទូលំទូលាយនៅឡើយ។ រាជរដ្ឋាភិបាលនៅមានភាពខ្វះចន្លោះ ឬស្ទាក់ស្ទើរក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានសាធារណៈ ដោយមូលហេតុមួយចំនួន រួមមានៈ កង្វះខាតធនធាន សមត្ថភាពមានកម្រិត និងភាពមិនច្បាស់លាស់អំពីអ្វីដែលចាត់ទុកថាជាព័ត៌មានសម្ងាត់ជាដើម បើទោះបីជាមានមូលដ្ឋានច្បាប់មួយចំនួនដែលបានកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ ក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានសាធារណៈក៏ដោយ។ ការមិនបញ្ចេញព័ត៌មានជាសាធរណៈ ទោះបីដោយមូលហេតុសមត្ថភាពរបស់ស្ថាប័នរដ្ឋនៅមានកម្រិតក្តី ដោយយន្តការសម្រាប់ការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មាននៅមានកង្វះខាតក្តី ឬដោយស្ថាប័នរដ្ឋមានភាព ស្ទាក់ស្ទើរក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបញ្ហាណាដែលរសើបក្តី តួយ៉ាងដូចជាករណីទាំងឡាយទាក់ទងនឹងដំណោះស្រាយដីសម្បទានសេដ្ឋកិច្ច គម្រោងរុករករ៉ែ និងបញ្ហាតាមរោងចក្រកាត់ដេរជាដើមទើបជារឿយៗ គេឃើញមាននូវរឿងរ៉ាវជាច្រើនដែលកើតចេញមកពីទំនាស់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ក៏ដូចជាវិសមភាពនៃអំណាចរវាងភាគីអ្នកក្រីក្រនៅជនបទ កម្មកររោងចក្រ និងអ្នកមានទ្រព្យសម្បត្តិ ក៏ដូចជាអ្នកមានអំណាច ផងដែរ។

ដោយមើលឃើញអំពីសារសំខាន់នៃការទទួលបានព័ត៌មាន ក្នុងការជួយទប់ស្កាត់ជម្លោះជាយថាហេតុ និងចូលរួមចំណែកលើកកម្ពស់កម្មវិធីនយោបាយកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជានោះអង្គការសង្គមស៊ីវិល និងប្រជាសហគមន៍ សូមជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភានីតិកាលទី៥ បង្កើនសមត្ថភាពស្ថាប័នសាធារណៈក្នុងការបើកចំហព័ត៌មាន ដោយផ្អែកលើមូលដ្ឋានច្បាប់ដែលមានស្រាប់ផង និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅពេលឆាប់ៗខាងមុខនេះដោយស្របទៅ តាមបទដ្ឋាន អន្តរជាតិ ផង។

សង្គមស៊ីវិល និងប្រជាសហគមន៍បាននិងកំពុងតាមដានយ៉ាងយកចិត្តដាក់ ហើយកត់សំគាល់ថាសិទ្ធិទទួលព័ត៌មាន ឬការបើកចំហព័ត៌មាន គឺជាបញ្ហាដែលមានផលប៉ះពាល់ដល់គ្រប់វិស័យទាំងអស់ តួយ៉ាងដូចជាវិស័យសេដ្ឋកិច្ច វិនិយោគ កសិកម្ម រ៉ែ វារីអគ្គិសនី បរិស្ថាន និងអភិវឌ្ឍន៍ទីក្រុងជាដើម។ ស្ថានភាពបច្ចុប្បន្ន នៃការអនុវត្តច្បាប់ព្រៃឈើ និងដីធ្លី ក៏ដូចជាការគ្រប់គ្រងធនធានធម្មជាតិ និងសិទ្ធិមនុស្ស សុទ្ធតែទទួលរងនូវផលប៉ះពាល់ពីកង្វះការបើកចំហ ព័ត៌មាន។ សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅពឹងអាស្រ័យខ្លាំងជាងគេ លើដីធ្លី និង ព្រៃឈើ

កំពុងប្រឈមនឹងបញ្ហាចុះបញ្ជីដីសមូហភាព និងសហគមន៍តំបន់ការពារ ក៏ដូចជាបញ្ហាសម្បទានដីសេដ្ឋកិច្ច។ បញ្ហាវិវាទដីធ្លី ក៏ជាប់ជាមួយគ្នានឹងបញ្ហាបណ្តេញចេញដោយបង្ខំផងដែរហើយបញ្ហាទាំងអស់នោះសុទ្ធតែទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន ឬការបើកចំហព័ត៌មាន។ ដូច្នេះដំណោះស្រាយណាមួយនូវសិទ្ធិទទួលព័ត៌មាន គឺជាការរួមចំណែកដោះស្រាយនូវបញ្ហាទាំងប៉ុន្មានដែល បានរៀបរាប់ខាងលើ បើទោះបីជាមិនបានទាំងស្រុងក៏ដោយ។

សមិទ្ធិផលរបស់រាជរដ្ឋាភិបាល

អង្គការសង្គមស៊ីវិល និងប្រជាសហគមន៍ទទួលស្គាល់ការខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការលើកកំពស់សិទ្ធិទទួលព័ត៌មាន ជាពិសេសនៅថ្នាក់ក្រោមជាតិ តាមរយៈកម្មវិធីមួយចំនួនដូចជាកម្មវិធីអភិបាលកិច្ចល្អមូលដ្ឋាន ក្របខ័ណ្ឌគណនេយ្យភាពសង្គម កម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងច្រកចេញចូលតែមួយជាដើម។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមដំណើរការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ត្រូវបានកោតសរសើរ ក៏ពិតមែនហើយ ក៏ប៉ុន្តែសង្គមស៊ីវិលចង់ឲ្យរាជរដ្ឋាភិបាលធ្វើច្បាប់នេះឲ្យបានឆាប់ និងធានាថាជាច្បាប់មួយដែលល្អ។ ជាមួយគ្នានេះដែរ ក្នុងខណៈដែលច្បាប់មិនទាន់មាននោះការពង្រឹងការអនុវត្តន៍បទដ្ឋានច្បាប់ដែលមានរួចស្រាប់មកហើយ ក៏អាចរួមចំណែកបានមួយផ្នែកធំក្នុងកាត់បន្ថយ និង បញ្ចៀសបញ្ហាទាំងឡាយដែលបានរៀបរាប់ខាងលើ។ ខាងក្រោមនេះគឺជាអនុសាសន៍មួយចំនួនរបស់សង្គមស៊ីវិល និងប្រជាសហគមន៍ ជូនចំពោះរាជរដ្ឋាភិបាល។

អនុសាសន៍

១. ក្រសួង មន្ទីរ និងអង្គភាពនានារបស់រដ្ឋ ត្រូវបើកចំហព័ត៌មានសាធារណៈ ជាពិសេស តម្លៃសេវាកម្ម នីតិវិធីក្នុងការទទួលបានសេវា និងពេលវេលាកំណត់ដោយច្បាប់
២. ពង្រឹងសមត្ថភាពស្ថាប័ន និងបង្កើតនូវយន្តការទាំងឡាយដើម្បីធានាថាប្រជាជនកម្ពុជានឹងទទួលបានព័ត៌មានពេញលេញ
៣. អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដោយមានការចូលរួមពិគ្រោះយោបល់ឲ្យបានទូលំទូលាយ និងទទួលយកនូវអនុសាសន៍ពីស្ថាប័នសង្គមស៊ីវិលពាក់ព័ន្ធ ថែមទាំង បញ្ជាក់ឱ្យបានច្បាស់ អំពីព័ត៌មានណាដែលត្រូវរក្សាជាសម្ងាត់។
៤. បង្កើនសមត្ថភាពបុគ្គលិករាជរដ្ឋាភិបាលក្នុងការផលិត និងចែកចាយព័ត៌មាន
៥. ផ្តល់កិច្ចការពារចំពោះប្រជាពលរដ្ឋគ្រប់រូបដែលបានបង្ហាញ និងចែកចាយនូវព័ត៌មានពិតប្រាកដ ឬព័ត៌មានទាំងឡាយណាដែលបម្រើដល់ប្រយោជន៍សាធារណៈ
៦. ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពី សិទ្ធិទទួលបានព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងការស្វែងរកព័ត៌មានសាធារណៈទាំងឡាយដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ
៧. បង្កើតឱ្យមានបរិយាកាសអំណោយផលប្រសើរជាងមុន សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

- អ្នកស្រី **វ៉េន សាមីន** សហគមន៍មកពីខេត្តកំពង់ស្ពឺ លេខទូរស័ព្ទ 097 9012 869
- លោក **ក្រោស សុខ** សហគមន៍មកពីខេត្តមណ្ឌលគិរី លេខទូរស័ព្ទ 096 4203 097
- លោក **សល់ សុផាត** សហគមន៍មកពីខេត្តរតនគិរី លេខទូរស័ព្ទ 097 2709 705
- លោក **គល់ ចាន់នី** សហគមន៍មកពីខេត្តស្ទឹងត្រែង លេខទូរស័ព្ទ 092 509 879
- លោកស្រី **សូ សុផល្លា** សហគមន៍មកពីភ្នំពេញ លេខទូរស័ព្ទ 012 702 914
- លោក **ឡាត់ គី** ប្រធាន ផ្នែកដីធ្លី និងជីវភាព សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) លេខទូរស័ព្ទ 012 828 411
- លោក **សួន ប៊ុនស័ក្តិ** ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) លេខទូរស័ព្ទ 092 344 357
- លោក **ឡាំ សុជាតិ** នាយករង វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) លេខទូរស័ព្ទ 077 555 679
- លោក **តឹក វណ្ណារ៉ា** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) លេខទូរស័ព្ទ 012 793 489
- លោក **ម៉ម សម្បត្តិ** នាយកប្រតិបត្តិ អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA) លេខទូរស័ព្ទ 012 779 734
- លោកស្រី **គឹម ណាតាសា** នាយករងកម្មវិធី សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធា (CRRT) លេខទូរស័ព្ទ 012 513 802
- លោក **ប៉ែន សុមុន្នី** នាយកប្រតិបត្តិ អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS) លេខទូរស័ព្ទ 012 708 093
- លោក **សៀ ភារម្យ** នាយកលេខាធិការដ្ឋាន ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) លេខទូរស័ព្ទ 012 852 325
- លោក **សៅ វណ្ណសី** នាយកប្រតិបត្តិ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) លេខទូរស័ព្ទ 012 813 744
- លោក **ឈួន បូរិទ្ធ** នាយកប្រតិបត្តិ អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍សង្គម (KYSD) លេខទូរស័ព្ទ 012 798 488
- លោក **មិន ស** នាយកប្រតិបត្តិ អង្គការជីវិតថ្លៃថ្នូរ (LWD) លេខទូរស័ព្ទ 012 329 926
- លោកស្រី **ជេត ចរិយា** នាយិកាប្រតិបត្តិ អង្គការស្តារកម្ពុជា (Star Kampuchea) លេខទូរស័ព្ទ 012 802 460
- លោក **ជាង សុខា** នាយកប្រតិបត្តិ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) លេខទូរស័ព្ទ 012 360 464
- លោកស្រី **អេង ស្មើ** តំណាងអង្គការទស្សនៈពិភពលោក (WVC) លេខទូរស័ព្ទ 011 332 335
- លោក **គឹម សុវណ្ណ** នាយកប្រតិបត្តិអង្គការវីជីឡែន លេខទូរស័ព្ទ 012 957 282

Appendix Three: Open speech by H.E. Dr. Mong Reththy

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
គណៈកម្មការ ទី៣

សុន្ទរកថាបើក

សន្និសីទថ្នាក់ជាតិលើកទី៨ ស្ដីពី "ធ្វើការរួមគ្នាដើម្បីជម្រុញកំណែទម្រង់ លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា"

ថ្លែងដោយ ឯកឧត្តម បណ្ឌិត ម៉ុង ឫទ្ធី ប្រធានគណៈកម្មការទី៣
នៃព្រឹទ្ធសភាព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤
សណ្ឋាគារ អ៊ីមរតីរៀល ភ្នំពេញ

សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីគោរព និងជាទីរាប់អាន

ថ្ងៃនេះ តាងនាម **សម្ដេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបានចូលរួមធ្វើជាអធិបតីក្នុងសន្និសីទថ្នាក់ជាតិលើកទី៨ ស្ដីពី *"ធ្វើការរួមគ្នាដើម្បីជម្រុញ កំណែទម្រង់លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា"* នាឱកាសរកនាពេលនេះ។

ជាបឋម ខ្ញុំសូមកោតសរសើរយ៉ាងក្រៃលែងចំពោះគណៈកម្មការរៀបចំសន្និសីទថ្នាក់ជាតិនេះឡើង ក្នុងគោលបំណងឆ្លុះបញ្ចាំងលើការ លើកស្ទួយអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលអាណត្តិទី៥ (២០១៤-២០១៨) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ។

ទិសដៅរួមរបស់ព្រឹទ្ធសភា រដ្ឋសភាជាតិ ក៏ដូចជា រាជរដ្ឋាភិបាលកម្ពុជា គឺកសាងនូវសង្គមកម្ពុជាមួយ ដែលរឹងមាំ មានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម មានការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារភ្ជាប់គ្នានិងត្រូវបានពង្រឹងដើម្បីធានាថា ប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និងមានសុខភាពល្អ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងសង្គមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភានិងព្រឹទ្ធសភា នឹងប្ដេជ្ញាចិត្តយ៉ាងពេញទំហឹង ដើម្បីថែរក្សាការពារសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គមសម្រាប់លើកកម្ពស់ការអនុវត្តច្បាប់ និងការគោរពសិទ្ធិមនុស្ស សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មានកំណើនសេដ្ឋកិច្ច រយៈពេលវែង និងគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855-23) 211 117 E-mail : mongreththy@live.com

ដោយផ្អែកលើបទពិសោធន៍ និងលទ្ធផលសម្រេចបានក្នុងនីតិកាលទី៤ និង **"កម្មវិធីនយោបាយ"** សម្រាប់នីតិកាលទី៥ របស់ខ្លួន រាជរដ្ឋាភិបាលយល់ឃើញថា យុទ្ធសាស្ត្រចតុកោណជាពិសេសគោលដៅសម្រាប់ **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** នៅតែចាំបាច់និងសមស្របសម្រាប់កម្ពុជា បន្តអនុវត្តនៅក្នុងនីតិកាលទី៥ (២០១៣-២០១៨)ទៀត ដោយ រក្សាទុកនូវចតុកោណទាំងបួនឲ្យនៅដដែល ប៉ុន្តែពង្រីកវិសាលភាព សម្រិតសម្រាំង ធ្វើអាទិភាវូបនីយកម្មមុំ ព្រមទាំងកែ លម្អគោលនយោបាយ និងយន្តការមួយចំនួនឲ្យកាន់តែសុក្រឹតឡើងថែមទៀត។ **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** បានបញ្ជាក់ច្បាស់អំពីបេសកកម្ម និងការប្តេជ្ញាចិត្តយ៉ាងមុឹងមាំរបស់រាជរដ្ឋាភិបាលក្នុងការធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងបរិការណ៍ថ្មីៗ ទាំងកម្រិតជាតិ និង ទាំងកម្រិតអន្តរជាតិ។

ក្នុងន័យនេះ **"កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា"** និង **"យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣"** រួមជាមួយគ្នាគឺជាឯកសារក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំ **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ"** ដោយកំណត់សូចនាករ និងពេលវេលាច្បាស់លាស់សម្រាប់អនុវត្តដែលមានសង្គតិភាពជាមួយនឹងឯកសារគោល នយោបាយតាមវិស័យដទៃទៀតរបស់រាជរដ្ឋាភិបាល។ ដូច្នេះ **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** គឺជាឯកសារ មគ្គុទេសក៍ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ច អភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់រយៈពេលវែងសំដៅ ជម្រុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផល នៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឲ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធាន គ្រប់ប្រភេទឲ្យបានស្ថិតថេរចេរកាលសម្រាប់កូនចៅយើងយូរអង្វែងតទៅ។

សម្រាប់នីតិកាលទី៥នេះ ទាំងព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលនៅតែចាត់ទុកថា **"អភិបាលកិច្ចល្អ"** នៅតែ ជាស្នូលនៃយុត្តិធម៌សង្គម និងការអភិវឌ្ឍន៍ សង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ដើម្បីពង្រឹងអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តកំណែទម្រង់ដោយឥតរាថយ ក្នុងវិស័យសំខាន់ៗរួមមាន (១)ការប្រយុទ្ធប្រឆាំងនឹងអំពើពុក រលួយ កំណែទម្រង់(២) ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ (៤)កំណែទម្រង់រដ្ឋបាលសាធារណៈ និង(៣)ប្រដាប់ អាវុធ។ ទិសដៅសំខាន់បំផុតនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ដីធ្លី កំណែទម្រង់ព្រៃឈើ និង កំណែទម្រង់ជលផល គឺដើម្បីពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងារ និងពង្រឹងគុណភាពនៃសេវាសាធារណៈឲ្យកាន់តែ ប្រសើរឡើងដើម្បីបង្កើនជំនឿទុកចិត្ត និងឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ប្រជាជន និងសហគមន៍ ធុរកិច្ចទាំងជាតិនិងអន្តរជាតិ។

ជាថ្មីម្តងទៀតជូនដល់គណៈកម្មការរៀបចំសន្និសីទនេះ ដែលបានផ្តល់ឱកាសឲ្យខ្ញុំបាទបានថ្លែងបទអន្តរាគមន៍នៅ ក្នុងវេទិកាដ៏មានសារៈសំខាន់ ហើយទន្ទឹមនឹងនេះ ខ្ញុំបាទមានជំនឿនិងក្តីសង្ឃឹមយ៉ាងមុតមាំថា ការពិភាក្សាលើប្រធាន បទ *"ធ្វើការរួមគ្នាដើម្បីជម្រុញ កំណែទម្រង់លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព នៅកម្ពុជា"* និងមានចេញជាអនុសាសន៍បន្ថែមទៀតក្នុងការយកមកធ្វើជាដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ ទទួលបាន នូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកអង្គសន្និសីទថ្នាក់ជាតិនេះ ចាប់ពីពេលនេះតទៅ។

សូមអរគុណ

Appendix four: Welcome remarks by Dr Tek Vannara

សុន្ទរកថាស្វាគមន៍

បណ្ឌិត តឹក វណ្ណារ៉ា

នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

ថ្លែងក្នុងសន្និសីទតស៊ូមតិថ្នាក់ជាតិលើកទី ៨ ស្តីពី

"ធ្វើការរួមគ្នាដើម្បីជំរុញកំណែទម្រង់ លើអភិបាលកិច្ចដីធ្លី

និងធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា"

ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ អ៊ីមភើរៀល-រ័ឡា ភ្នំពេញ

សូមគោរព

- ឯកឧត្តមបណ្ឌិត ម៉ុង ឬទ្ធី ប្រធានគណៈកម្មការទី៣នៃព្រឹទ្ធសភា
- ឯកឧត្តម លោកជំទាវ ដែលអញ្ជើញមកពីស្ថាប័នរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងវិស័យឯកជន
- លោកស្រី Anu Riikonen តំណាង Fin Church Aid ប្រចាំនៅកម្ពុជា
- លោកស្រី Sandra Stajka តំណាង USAID ប្រចាំនៅកម្ពុជា
- លោក សួន ប៊ុនស័ក្តិ ប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា
- លោក-លោកស្រី អ្នកនាងកញ្ញា តំណាងដៃគូរអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ - អន្តរជាតិ និងភ្ញៀវកិត្តិយស
- បងប្អូនប្រជាពលរដ្ឋ និង តំណាងជនជាតិដើមភាគតិច ជាទីរាប់អាន!

តាងនាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងគណៈកម្មការរៀបចំ ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់**ឯកឧត្តមបណ្ឌិត ម៉ុង ឬទ្ធី ប្រធានគណៈកម្មការទី៣នៃព្រឹទ្ធសភា**ដែលបានចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃ ចូលរួមថ្លែងសុន្ទរកថាបើកអង្គសន្និសីទនាថ្ងៃនេះ និងវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមក្នុងសន្និសីទតស៊ូមតិថ្នាក់ ជាតិ លើកទី៨ស្តីពី "ធ្វើការរួមគ្នាដើម្បីជំរុញកំណែទម្រង់លើអភិបាលកិច្ចដីធ្លីនិងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា"។

1

សន្និសីទតស៊ូមតិថ្នាក់ជាតិ លើកទី៨នេះ បានសហការរៀបចំឡើងដោយបណ្តាញអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៦ រួមមាន៖ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API), គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC), សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន(CRRT), អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS), អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA), អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GADC), ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF), អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO), អង្គការយុវជនខ្មែរដើម្បីអភិវឌ្ឍន៍សង្គម (KYSD), អង្គការជីវិតថ្លៃថ្នូរ(LWD), អង្គការស្តារកម្ពុជា(STAR Kampuchea), វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia), អង្គការទស្សនៈពិភពលោក (WVC) អង្គការUPWD និងអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)។

អង្គការដែលជាគណៈកម្មការរៀបចំសន្និសីទនាថ្ងៃនេះ បាននិងកំពុងធ្វើការរួមគ្នាដើម្បីកែលម្អការអនុវត្តន៍ និងការផ្តល់សេវាកម្ម ដែលបានចូលរួមចំណែកដល់ការគោរពសិទ្ធិមនុស្ស អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ និងនិរន្តរភាពនៃបរចិញ្ចឹមជីវិតរបស់ពលរដ្ឋកម្ពុជា។ សន្និសីទនេះ គឺជាព្រឹត្តិការណ៍មួយដ៏សំខាន់ដែលផ្តល់ឱកាសសម្រាប់សហគមន៍ សង្គមស៊ីវិល រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នសិក្សាស្រាវជ្រាវ និងអ្នកតាក់តែងច្បាប់ជួបជុំគ្នា ដើម្បីជជែកពិភាក្សាគ្រង់ទៅ គ្រង់មកក្នុងន័យស្ថាបនាលើបញ្ហា និងកង្វល់នានា ក៏ដូចជាការស្វែងរកនូវការយល់ដឹង និងយុទ្ធសាស្ត្ររួមគ្នាសំដៅសម្រេចឲ្យបានក្នុងការជំរុញកំណែទម្រង់លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន!

ប្រជាជនកម្ពុជាប្រមាណ ៨០% រស់នៅតំបន់ជនបទ គឺពឹងអាស្រ័យលើធនធានធម្មជាតិ ប្រកបរបរកសិកម្ម និងអនុផលព្រៃឈើ ដែលជាប្រភពនៃមុខរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀងរបស់ពួកគាត់។ ចំពោះប្រជាពលរដ្ឋកម្ពុជា ដែលរស់នៅតំបន់ជនបទបានចាត់ទុកថា "**ដីគឺជាអាយុជីវិត**" ហេតុនេះយើងទាំងអស់គ្នា ចាំបាច់ត្រូវរួមគ្នាជួយការពារ និងគ្រប់គ្រងឲ្យបានល្អ ដើម្បីធានានូវសុវត្ថិភាពដីធ្លីជូនពួកគាត់។ អង្គការសង្គមស៊ីវិលយល់ថា ការអនុវត្តច្បាប់ត្រឹមត្រូវ ការតាមដាន និងត្រួតពិនិត្យជាប្រចាំលើការអនុវត្តសម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ គំរោងអភិវឌ្ឍន៍វារីអគ្គិសនីធំៗ កសិឧស្សាហកម្ម និងគំរោងអភិវឌ្ឍន៍ហេដ្ឋារចនា

សម្ព័ន្ធធំៗឲ្យបានត្រឹមត្រូវ និងស្របទៅតាមកិច្ចសន្យា គឺជាគន្លឹះសំខាន់មួយក្នុងការរួមចំណែកកាត់បន្ថយ និងដោះស្រាយជំលោះដីធ្លី និងធនធានធម្មជាតិ។ បន្ថែមពីលើនេះ ការពន្លឿនក្នុងការចុះបញ្ជី និងទទួលស្គាល់សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារ សហគមន៍ជនជាតិដើមភាគតិច សហគមន៍នេសាទ សហគមន៍អេកូទេសចរណ៍ ព្រមទាំងផ្តល់កញ្ចប់ថវិកាគ្រប់គ្រាន់សំរាប់លំហូរឲ្យសហគមន៍ទាំងនោះក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍របស់ខ្លួនផ្សារភ្ជាប់ជាមួយផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគឃុំ ក៏ជាចំនុចគន្លឹះដើម្បីជំរុញកំណែទម្រង់លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។ ជាពិសេស ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ក៏ជាចំនុចគន្លឹះមួយក្នុងការធានាឲ្យការអភិវឌ្ឍន៍ដំណើរការចំទិសដៅ កាត់បន្ថយនូវជំលោះ និងធានាដល់ការស្តារ និងការគ្រប់គ្រងបរិស្ថានល្អប្រសើរ ដូច្នេះអ្នកអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលគួរពង្រឹងយន្តការនេះឲ្យមានប្រសិទ្ធិភាព និងស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល សូមគាំទ្រចំពោះសេចក្តីប្រកាសអន្តរក្រសួងស្តីពីការពង្រឹងលើការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងពិនិត្យឡើងវិញនូវដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់។ អង្គការមិនមែនរដ្ឋាភិបាល សំណូមពរឲ្យការអនុវត្តន៍នូវសេចក្តីប្រកាសនេះ ប្រកបដោយតម្លាភាព និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

សន្និសីទនាថ្ងៃនេះ គឺជាឱកាសសម្រាប់ការពិភាក្សាក្នុងន័យស្ថាបនា រវាងតំណាងសហគមន៍ តំណាងអង្គការមិនមែនរដ្ឋាភិបាល តំណាងដៃគូរអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងស្ថាប័នសិក្សាស្រាវជ្រាវ តំណាងក្រសួងពាក់ព័ន្ធនានា តំណាងរដ្ឋសភា និងតំណាងព្រឹទ្ធសភា ព្រមទាំងរៀបចំរួមគ្នានូវអនុសាសន៍ និងសំណើគោលនយោបាយសំខាន់ៗ ដើម្បីរួមចំណែកដល់ផែនការអភិវឌ្ឍន៍ជាតិ និងការធានាឲ្យបាននូវអភិបាលកិច្ចល្អនិងពេញលេញលើដីធ្លី និងធនធានធម្មជាតិ។ ដំណើរការនៃការពិភាក្សា និងភាពជាដៃគូរ ប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធិភាព និងការទទួលខុសត្រូវ លុះណាតែមានតម្លាភាព ភាពជឿទុកចិត្តគ្នា និងការគោរពគ្នាទៅវិញទៅមក។ លើសពីនេះទៅទៀត យន្តការដែលមានស្រាប់សម្រាប់ការពិភាក្សារួមមានដូចជា ក្រុមការងារបច្ចេកទេស និងកិច្ចប្រជុំនានា គឺមានសារៈសំខាន់សម្រាប់ការពិភាក្សារវាងតួអង្គអភិវឌ្ឍផ្សេងៗ ក៏ប៉ុន្តែគួរតែពង្រឹងយន្តការនៃការពិភាក្សាបន្ថែមទៀត ដើម្បីធានានូវភាពជាដៃគូ ប្រកបដោយប្រសិទ្ធិភាពរវាងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល បានត្រៀមខ្លួនជាស្រេចសម្រាប់ការចូលរួមសហការជាមួយរដ្ឋាភិបាល វិស័យឯកជន និងដៃគូរអភិវឌ្ឍន៍ ដើម្បីចូលរួម

ចំណែកដោះស្រាយបញ្ហាដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធានានូវអភិបាលកិច្ចល្អលើធនធានធម្មជាតិ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន!

ឆ្លៀតក្នុងឱកាសដ៏ល្អប្រពៃនេះ តាងនាមគណៈកម្មការរៀបចំ និងខ្លួនខ្ញុំផ្ទាល់ សូមអបអរសាទរចំពោះយុទ្ធនាការបុពណ៌ស១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីក្រោមប្រធានបទ "គ្មានអំពើហិង្សា គឺជាការផ្លាស់ប្តូរឥរិយាបទរបស់អ្នក" ដែលនឹងចាប់ផ្តើមប្រារព្ធពីថ្ងៃនេះរហូតដល់ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០១៤។ នៅក្នុងកំឡុងពេលនៃយុទ្ធនាការនេះ បុពណ៌សត្រូវបានបំពាក់ឱ្យប្រជាពលរដ្ឋ ជាពិសេសបុរសដែលជាសញ្ញានៃការសន្យារបស់ពួកគេដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន!

តាងនាមគណៈកម្មការរៀបចំ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះវត្តមានរបស់**ឯកឧត្តមបណ្ឌិត ម៉ុង ឬទ្ធី ប្រធានគណៈកម្មការទី៣នៃព្រឹទ្ធសភា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួម និងផ្តល់សុន្ទរកថាបើកអង្គសន្និសីទនាថ្ងៃនេះ និងតែងតែផ្តល់ការសហការល្អជាមួយអង្គការមិនមែនរដ្ឋាភិបាល។ ខ្ញុំបាទក៏សូមថ្លែងអរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមសន្និសីទនាថ្ងៃនេះ។ ខ្ញុំបាទសូមថ្លែងអំណរគុណទុកជាមុន ចំពោះវត្តមានរបស់ឯកឧត្តមប្រធានគណៈកម្មការទី៣នៃរដ្ឋសភាដែលនឹងអញ្ជើញមកចូលរួមបិទអង្គសន្និសីទ និងថ្លែងអំណរគុណវាគ្មិនកិត្តិយសទាំងអស់ដែលនឹងធ្វើ បទបង្ហាញក្នុងអង្គសន្និសីទនាថ្ងៃនេះ។ លើសពីនេះទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ ដែលបានផ្តល់វិភាគទានក្នុងការរៀបចំអង្គសន្និសីទនេះ និងគណៈកម្មការរៀបចំសន្និសីទ និងក្រុមការងារទាំងអស់ដែលបានខិតខំប្រឹងប្រែងរៀបចំសន្និសីទនាថ្ងៃនេះ ប្រកបដោយភាពអធិកអធម។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរឯកឧត្តមគណៈអធិបតី លោក-លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់ឲ្យសម្រេចបានជោគជ័យគ្រប់ភារកិច្ច និងសូមជួបប្រទះនូវពុទ្ធពរបួនប្រការគឺ អាយុះ វណ្ណៈសុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

Appendix five: Presentation on Business and Human Right

25/11/2014

សិទ្ធិមនុស្ស និងធុរកិច្ច
គោលការណ៍ណែនាំ
របស់អង្គការសហប្រជាជាតិស្តីពី
ធុរកិច្ច និងសិទ្ធិមនុស្ស

សន្និសីទថ្នាក់ជាតិ លើកទី៨ ស្តីពី "ធ្វើការរួមគ្នាដើម្បីជំរុញកំណែទម្រង់លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា"

សេចក្តីផ្តើមអំពី ធុរកិច្ច និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

- ✓ ច្បាប់សិទ្ធិមនុស្សអន្តរជាតិនិយាយសំដៅកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព ការពារ និងធ្វើអោយទទួលបានសិទ្ធិមនុស្សពេញលេញ
- ✓ មានកង្វល់ជាច្រើនអំពីផលប៉ះពាល់អវិជ្ជមាននៃសាជីវកម្មពហុជាតិ ជាពិសេសកើតមានឡើងតាំងពីទសវត្សឆ្នាំ ១៩៧០
- ✓ មានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដោយអង្គការសហប្រជាជាតិដើម្បីឆ្លើយតប/ដោះស្រាយកង្វល់ទាំងនេះ។

ច្បាប់និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងធុរកិច្ច និងសិទ្ធិមនុស្ស

ចុងទសវត្សឆ្នាំ១៨០០	យុទ្ធនាការប្រឆាំងទាសករ និងពលកម្មកុមារ ([illegible])
ឆ្នាំ១៩១៩	ការបង្កើតឡើងអង្គការពលកម្មអន្តរជាតិ ILO
ឆ្នាំ១៩៤៨	សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
ឆ្នាំ១៩៦៦	ការបើកឱ្យរដ្ឋជាសមាជិកអ.ស.ប ចុះហត្ថលេខា ICCPR និង ICESR
ឆ្នាំ១៩៧៣	អ.ស.ប បង្កើតគណៈកម្មការស្តីពីសាជីវកម្មឆ្លងជាតិ (រំលាយចោលក្នុងឆ្នាំ១៩៩៤)
ឆ្នាំ១៩៧៦	ការចូលជាធរមាននូវ ICCPR និង ICESR ការអនុម័តនូវ OECD Guidelines for Multinational Enterprises
ឆ្នាំ១៩៩៨	អ.ស.ប បង្កើត ក្រុមការងារស្តីពីសាជីវកម្មឆ្លងជាតិ
ឆ្នាំ២០០៣	ការប៉ុនប៉ងរបស់ក្រុមស្តីពីការទទួលខុសត្រូវនៃសាជីវកម្មឆ្លងជាតិ និងសហគ្រាសពាណិជ្ជកម្មដទៃទៀត ទាក់ទងនឹងសិទ្ធិមនុស្ស (ក្រុមត្រូវបានបដិសេធក្នុងឆ្នាំ២០០៤)
ឆ្នាំ២០០៥	សាស្ត្រាចារ្យ ចន រ៉ុគី ត្រូវបានតែងតាំងជាតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និងសិទ្ធិមនុស្ស
ឆ្នាំ២០០៨	ក្របខ័ណ្ឌ ការពារ គោរព និងដោះស្រាយ ត្រូវបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស
ឆ្នាំ២០១១	គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស OECD Guidelines ត្រូវបានធ្វើបច្ចុប្បន្នភាព ដោយដាក់បញ្ចូលជំពូកស្តីពីសិទ្ធិមនុស្ស ។

ដំណើរឆ្ពោះទៅមុខលើសពីអ្វីដែលគ្រាន់តែជា'CSR'

ក្នុងខែមិថុនា ឆ្នាំ២០១១ អង្គការសហប្រជាជាតិ-ក្រុមប្រឹក្សាសិទ្ធិមនុស្ស អនុម័តជាឯកច្ឆ័ន្ទនូវសំណុំគោលការណ៍ណែនាំ ដើម្បីធានាថាក្រុមហ៊ុនមិនរំលោភសិទ្ធិមនុស្ស នៅក្នុងប្រតិបត្តិការសកម្មភាពធុរកិច្ចរបស់ខ្លួន និងធានាថាពួកគេផ្តល់នូវដំណោះស្រាយនៅពេលមានករណីរំលោភបំពានកើតឡើង។

2

អាណត្តិរបស់តំណាងពិសេស លោក ចន រូហ្គី

- ✓ លោកសាស្ត្រាចារ្យ ចន រូហ្គី ត្រូវក្រុមប្រឹក្សាសិទ្ធិមនុស្សផ្តល់អាណត្តិឲ្យ កំណត់ និងស្រាយបំភ្លឺអំពីស្តង់ដានៃការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសិទ្ធិមនុស្ស និងស្រាយបំភ្លឺអំពីតួនាទីរបស់រដ្ឋ
- ✓ ជំហានទី១ (ឆ្នាំ២០០៥-២០០៨)៖ បង្កើតនូវក្របខណ្ឌ "**ការពារ គោរព និងដោះស្រាយ**" ("ក្របខណ្ឌរូហ្គី")
- ✓ ជំហានទី២ (ឆ្នាំ២០០៨-២០១១)៖ បង្កើតនូវគោលការណ៍ណែនាំ អ.ស.ប ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស

ក្របខ័ណ្ឌ ការពារ គោរព និងដោះស្រាយ

(សសរស្តម្ភទាំង៣)

- ✓ រដ្ឋមានភារកិច្ចការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តិដោយភាគីទី៣ រួមមានទាំងធុរកិច្ច
- ✓ សហគ្រាសពាណិជ្ជកម្មមានការទទួលខុសត្រូវគោរពសិទ្ធិមនុស្សដែលតម្រូវឲ្យពួកគេប្រព្រឹត្តដោយត្រឹមត្រូវលើសិទ្ធិមនុស្ស ដើម្បីជៀសវាងពីការរំលោភបំពានសិទ្ធិមនុស្ស
- ✓ អ្នកដែលរងការរំលោភបំពានសិទ្ធិមនុស្សពីសំណាក់សហគ្រាសពាណិជ្ជកម្ម មានលទ្ធភាពទៅប្រើប្រាស់យន្តការដោះស្រាយប្រកបដោយប្រសិទ្ធិភាព (តាមប្រព័ន្ធតុលាការ និង/ឬក្រៅប្រព័ន្ធតុលាការ)

គោលការណ៍ណែនាំអ.ប.ស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច

- ✓ អនុម័តជាឯកច្ឆ័នដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងខែមិថុនា ឆ្នាំ២០១១
- ✓ មាន៣១ គោលការណ៍ សម្រាប់ណែនាំពន្យល់ដល់រដ្ឋ ធុរកិច្ច និង សហគមន៍អន្តរជាតិ អំពីការអនុវត្ត ក្របខណ្ឌ "ការពារ គោរព និង ដោះស្រាយ"
- ✓ បង្កើតឡើងនូវក្រុមការងារដើម្បីលើកកម្ពស់ និងត្រួតពិនិត្យមើលលើការអនុវត្តគោលការណ៍នែនាំនេះ
- ✓ វេទិកាប្រចាំឆ្នាំប្រព្រឹត្តិទៅនៅទីក្រុងហ្សឺណែវជាមួយអ្នកពាក់ព័ន្ធនានាដើម្បីយល់ដឹងពីភាពរីកចម្រើននៃគោលការណ៍នែនាំ។

ករណីដែលធុរកិច្ចគួរតែគោរពសិទ្ធិមនុស្ស

- ✓ហានិភ័យចំពោះប្រតិបត្តិការ
- ✓ប្រឈមនឹងបណ្តឹងផ្លូវច្បាប់
- ✓ហានិភ័យដល់កេរ្តិ៍ឈ្មោះ

ការទទួលខុសត្រូវ និងការប្រព្រឹត្តិយ៉ាងត្រឹមត្រូវលើសិទ្ធិមនុស្សរបស់សាជីវកម្ម

សហគ្រាសពាណិជ្ជកម្មគួរមានរួចជាស្រេចនូវ៖

- ✓ ការប្តេជ្ញាចិត្តខាងគោលនយោបាយ ដើម្បីបំពេញការទទួលខុសត្រូវគោរពសិទ្ធិមនុស្ស
- ✓ ដំណើរការនៃការពិនិត្យដោយត្រឹមត្រូវលើសិទ្ធិមនុស្ស-*មានន័យថាធុរកិច្ចធានានូវការអនុវត្តតាមច្បាប់ និងគ្រប់គ្រងបាននូវហានិភ័យនៃការរំលោភសិទ្ធិមនុស្ស*
- ✓ ដំណើរការដែលជួយដល់ការដោះស្រាយទៅលើផលប៉ះពាល់សិទ្ធិមនុស្សជាអវិជ្ជមានដែលធុរកិច្ចបង្ក ឬចូលរួមចំណែក រួមទាំងប្រើប្រាស់ឥទ្ធិពលខ្លួន

ការប្តេជ្ញាចិត្តខាងគោលនយោបាយ

- ❑ បំពេញការទទួលខុសត្រូវគោរពសិទ្ធិមនុស្សត្រូវមាននូវការប្តេជ្ញាចិត្តខាងគោលនយោបាយ(គោលការណ៍ ១៦) តាមរយៈសេចក្តីថ្លែងខាងគោលនយោបាយដែល៖
  - ✓អនុម័តដោយថ្នាក់គ្រប់គ្រងជាន់ខ្ពស់នៃសហគ្រាស
  - ✓ចែងអំពីការរំពឹងទុករបស់សហគ្រាសចំពោះសិទ្ធិមនុស្ស
  - ✓សាធារណៈជនអាចរកមើលបាន និងមានការដឹងលឺដល់បុគ្គលិក ដៃគូធុរកិច្ច និងភាគីភាក់ព័ន្ធដទៃទៀត
  - ✓ឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍ការអនុវត្ត និងនីតិវិធី

ការពិនិត្យដោយត្រឹមត្រូវលើសិទ្ធិមនុស្ស
(គោលការណ៍ណែនាំលេខ១៥-១៩)

ការប្រព្រឹត្តិដោយត្រឹមត្រូវលើសិទ្ធិមនុស្សគួរបញ្ចូលនូវ៖

- ✓ ការកំណត់ និងវាយតំលៃអំពីផលប៉ះពាល់ជាក់ស្តែង និងជាសក្តានុពលលើសិទ្ធិមនុស្ស
- ✓ បូកបញ្ចូលទៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួន និងចាត់វិធានការលើការរកឃើញអំពីផលប៉ះពាល់
- ✓ តាមដានការអនុវត្តពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និង
- ✓ ប្រាស្រ័យទាក់ទងនិងការឆ្លើយតបជាសាធារណៈអំពីការដោះស្រាយផលប៉ះពាល់សិទ្ធិមនុស្ស

ជារួមធុរកិច្ចគោរពសិទ្ធិមនុស្សគឺ៖

- ✓ អនុវត្តច្បាប់
- ✓ គោរពសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាអន្តរជាតិទាំងអស់
- ✓ អនុវត្តដំណើរការនៃការប្រព្រឹត្តដោយត្រឹមត្រូវលើសិទ្ធិមនុស្ស
- ✓ ពិគ្រោះយោបល់ជាមួយអ្នកដែលអាចនឹងរងផលប៉ះពាល់
- ✓ ធ្វើអោយមានការអនុវត្តតាមគោលការណ៍ណែនាំក្នុងសង្វាក់ផលិតកម្ម
- ✓ បង្កើតនូវយន្តការប្រកបដោយប្រសិទ្ធិភាពដោះស្រាយបណ្តឹង/ទំនាស់
- ✓ មានតម្លាភាពចំពោះគោលនយោបាយ សកម្មភាព និងផលប៉ះពាល់សិទ្ធិមនុស្ស និង
- ✓ ធ្វើសេចក្តីរាយការណ៍ជាសាធារណៈអំពីបញ្ហាសិទ្ធិមនុស្ស

ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងយន្តការដោះស្រាយបណ្ដឹង

- ✓ ភារកិច្ចរបស់រដ្ឋក្នុងការការពារ គឺតម្រូវឲ្យរដ្ឋចាត់វិធានការសមស្រប នានាដើម្បីធានានូវការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព (លេខ២៥)
- ✓ សហគ្រាសពាណិជ្ជកម្មគួរមានរួចជាស្រេចនូវយន្តការឬនីតិវិធីទទួល និងឆ្លើយតបចំពោះបណ្ដឹងសិទ្ធិមនុស្ស (លេខ ២២ និង ២៩-៣១)
- ✓ យន្តការរបស់រដ្ឋ និងយន្តការក្រៅក្របខ័ណ្ឌរដ្ឋ
- ✓ ជម្រើសសមស្របផ្សេងៗដែលមានប្រសិទ្ធិភាពដើម្បីដោះស្រាយទំនាស់

យន្តការក្រៅប្រព័ន្ធតុលាការ

- ✓ ជាលក្ខណៈរដ្ឋបាល ឬលក្ខណៈសមស្របដទៃទៀត
- ✓ យន្តការមានប្រសិទ្ធិភាពដែលបំពេញឲ្យយន្តការតុលាការ
- ✓ យន្តការទាំងនេះអាចមានទម្រង់ផ្សេងៗ៖
  - ✓ ជាលក្ខណៈការផ្សះផ្សា
  - ✓ ជាលក្ខណៈវិនិច្ឆ័យ
  - ✓ ផ្អែកលើភាពសមស្របនៃវប្បធម៌ ឬដំណើរការដែលផ្ដោតលើសិទ្ធិ

ឧទាហរណ៍៖

- ✓ ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ
- ✓ ប្រព័ន្ធដោះស្រាយទំនាស់ការងារ-ក្រុមប្រឹក្សាអជ្ញាកណ្ដាល
- ✓ គណកម្មការសុរិយោដី(វិវាទដីធ្លី)
- ✓ គណៈកម្មាការសិទ្ធិមនុស្សកម្ពុជា
- ✓ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ✓ អង្គភាពប្រឆាំងអំពើពុករលួយ
- ✓ នីតិវិធីដោះស្រាយបណ្ដឹងរបស់ក្រសួងមួយ ឬរបស់គណៈកម្មការអន្តរក្រសួង
- ✓ គណកម្មការដោះស្រាយបញ្ហាជាក់លាក់ផ្សេងទៀតដែលសមស្រប

យន្តការក្រៅពីផ្នែកតុលាការ

តើស្របច្បាប់ឬទេ?
-មានការទទួលខុសត្រូវ និងទំនុកចិត្ត

លក្ខណៈវិនិច្ឆ័យចំពោះប្រសិទ្ធិភាព

តើអាចទៅប្រើប្រាស់បានឬទេ?
-ស្គាល់ដោយគ្រប់ភាគីពាក់ព័ន្ធដែលជួយដល់ការចូលរួមរបស់ពួកគេ

តើមានសមិតភាព (ឥតទ្រេ) និងសិទ្ធិនានាឬទេ?
-ដំណោះស្រាយស្របទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

តើអាចព្យាករណ៍ទុកឬទេ?
-មានកាលបរិច្ឆេទ និងនីតិវិធីច្បាស់លាស់

តើមានសមធម៌ឬទេ?
-មាននីតិវិធីប្រកបដោយយុត្តិធម៌ និងមានការជូនដំណឹងច្បាស់លាស់ ការសំរេចចិត្តប្រកបដោយការចូលរួម

តើមានលក្ខណៈជាការសន្ទនាគ្នា និងដោយការចូលរួមឬទេ?

តើមានតម្លាភាពឬទេ?
ការប្រាស្រ័យទាក់ទងដោយចំហរ និងដោយមានការកសាងទំនុកចិត្ត

យន្តការក្រៅក្របខ័ណ្ឌរបស់រដ្ឋ

- ✓ដើម្បីបំពេញយន្តការដោះស្រាយរបស់រដ្ឋ-បង្កើតឡើងនូវយន្តការក្រៅក្របខ័ណ្ឌរដ្ឋ
- ✓ការទៅប្រើប្រាស់ និងការទទួលបានដំណោះស្រាយអាចមានល្បឿនលឿន និងកាត់បន្ថយចំណាយបានច្រើន
- ✓អាចទៅប្រើប្រាស់ជាលក្ខណៈឆ្លងដែន

កម្រិតប្រតិបត្តិការ

កម្រិតអ្នកពាក់ព័ន្ធពហុភាគី/កម្រិតថ្នាក់ឧស្សាហកម្ម

ស្ថាប័នអន្តររដ្ឋាភិបាលថ្នាក់តំបន់

ស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់និងអន្តរជាតិ

កម្រិតអន្តរជាតិ

ស្ថាប័នសិទ្ធិមនុស្ស ថ្នាក់ជាតិ តំបន់ អន្តរជាតិ

- ❑អាស៊ាន
- ❑អឺរ៉ុប
- ❑អាហ្វ្រិក

ស្ថាប័នសិទ្ធិមនុស្សជាតិ (ឯករាជ្យ)៖ គឺជាស្ថាប័នឯករាជ្យដែលបង្កើតឡើងដោយរដ្ឋាភិបាល ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស នៅក្នុងប្រទេស

- ✓ អាចត្រូវបានបង្កើតឡើងតាមច្បាប់ ឬតាមបញ្ញត្តិមានចែងក្នុងរដ្ឋធម្មនុញ្ញ
- ✓ ត្រូវតែស្របតាមគោលការណ៍ទីក្រុងប៉ារីស និងត្រូវបានទទួលស្គាល់ភាពស្របច្បាប់ដោយស្ថាប័នត្រួតពិនិត្យអន្តរជាតិ (ការផ្តល់កម្រិត A, B, C)

✓ ឧទាហរណ៍នៃប្រទេសដែលស្ថាប័នសិទ្ធិមនុស្សជាតិមានការទទួលស្គាល់ភាពស្របច្បាប់ជាអន្តរជាតិ ហើយដែលក្រុមហ៊ុនមកពីប្រទេសទាំងនេះកំពុងធ្វើវិនិយោគ ឬមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា

កាណាដា ថៃ អូស្ត្រាលី **សហរដ្ឋអាមេរិក** កូរ៉េ ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ញូស៊ីឡែន ន័រវេស ហ្វីលីពីន ដាណឺម៉ាក បារាំង អាល្លឺម៉ង់ លុចសំបួរ ហូឡង់ ចក្រភពអង់គ្លេស រុស្ស៊ី បែលហ្ស៊ិក ស៊ុយអែត

កម្រិតអន្តរជាតិ-យន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

❑ ស្ថាប័នសន្ធិសញ្ញា៖ ជាស្ថាប័នជំនាញខាងត្រួតពិនិត្យមើលលើការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋាភិបាល និងទទួលបណ្តឹងបុគ្គល។ ការនៅប្រើប្រាស់៖ ត្រូវតែប្រើអស់គ្រប់ផ្លូវដោះស្រាយនៅក្នុងស្រុកជាមុន/របាយការណ៍ពីអង្គការមិនរដ្ឋាភិបាលអាចដាក់បាន

- ✓ ក្រុមប្រឹក្សាសិទ្ធិមនុស្ស, គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ គណៈកម្មាធិការស្តីពីសិទ្ធិកុមារ ធ្វើការឃ្លាំមើលលើកាតព្វកិច្ចរបស់រដ្ឋចំពោះធុរកិច្ច (ការអនុវត្តបានក្រៅដែនដី?)

❑ នីតិវិធីពិសេស៖ អ្នកជំនាញការឯករាជ្យ ទទួលបណ្តឹង (ទាំងបណ្តឹងពាក់ព័ន្ធនឹងការរំលោភបំពានដោយធុរកិច្ច) និងធ្វើទស្សនកិច្ចតាមប្រទេស។ ការនៅប្រើប្រាស់៖ គ្រប់ៗគ្នាអាចផ្ញើព័ត៌មានបាននៅគ្រប់ពេលវេលា

- ✓ ឧទាហរណ៍៖ សិទ្ធិលំនៅដ្ឋាន ជនជាតិដើមភាគតិច ការបំពុលបរិយាកាស អាហារ ទឹក និងអនាម័យ អ្នកការពារសិទ្ធិមនុស្ស (ក្រុមការងារស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស)

❑ ការពិនិត្យរបាយការណ៍រដ្ឋភាគីជាសកលតាមកាលកំណត់៖ ជាវេទិកាពិនិត្យមើលការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សធ្វើដោយរដ្ឋជាសមាជិកសហប្រជាជាតិ។ ការនៅប្រើប្រាស់៖ ជាការពិនិត្យធ្វើឡើងដោយរដ្ឋឯងគ្នា, អង្គការមិនមែនរដ្ឋាភិបាលអាចដាក់ជូនព័ត៌មានផ្សេងៗបាន

ការត្រួតពិនិត្យ និងការទទួលបណ្តឹងរបស់ ILO (ហ្ស៊ីណេវ)

- ជាប្រព័ន្ធនៃនាំអំពីបទដ្ឋាន (ស្ថាប័នត្រួតពិនិត្យ)
  - គណៈកម្មាធិការជំនាញដែលធ្វើការត្រួតពិនិត្យជាទៀងទាត់ការអនុវត្តរបស់រដ្ឋចំពោះកាតព្វកិច្ចសន្ធិសញ្ញាពាក់ព័ន្ធនឹងការងារ
  - ចេញសេចក្តីអង្កេត (ផ្តល់យោបល់អំពីរបៀបដែលរដ្ឋ ត្រូវគោរពបទបញ្ញត្តិចែងក្នុងសន្ធិសញ្ញា ក្នុងការអនុវត្តជាក់ស្តែង) និងធ្វើសំណើដោយផ្ទាល់ (សំណើរបែបបច្ចេកទេស សម្រាប់ការតាមដាន)
  - សន្និសីទអន្តរជាតិស្តីពីការងារ ធ្វើឡើងជារៀងរាល់ឆ្នាំរវាង រដ្ឋ និយោជក និងកម្មករ (បូកបន្ថែមទាំងអង្គការមិនមែនរដ្ឋាភិបាលដែលមានការទទួលស្គាល់ដែលជ្រើសរើសមួយចំនួន)
- រចនាសម្ព័ន្ធត្រីភាគី (រដ្ឋ/និយោជក/និយោជិតកម្មករ)
  - អង្គការមិនមែនរដ្ឋាភិបាលជាតិអាចគាំទ្រដល់រចនាសម្ព័ន្ធនេះ ដោយការពង្រឹងដល់សហជីព ដោយការប្រាស្រ័យទាក់ទងជាមួយនិយោជកនានា ជួយរដ្ឋាភិបាលធ្វើឲ្យប្រសើរឡើងដល់បទដ្ឋាននា

យូអិនគ្លូបលកំផែក (UN Global Compact)

និយមន័យ៖ ជាវេទិកាមួយសម្រាប់ធុរកិច្ច (ជាមួយសមាគមន៍ធុរកិច្ច សង្គមស៊ីវិល សហជីពពាណិជ្ជកម្ម រដ្ឋាភិបាល) ដើម្បីចងជាបណ្តាញ និងធ្វើការពាក់ព័ន្ធលើគោលការណ៍ចំនួន ១០ ស្តីពីសិទ្ធិមនុស្ស ការងារ បរិស្ថាន ប្រឆាំងអំពើពុករលួយ

- មានធុរកិច្ចចំនួន ៧.០០០ នៅក្នុងប្រទេសចំនួន ១៤៥ (សមាជិកសរុប ១០.០០០)
- វិបានការសុចរិតភាពរបស់UN Global Compact (ការឆ្លើយតបរបស់ក្រុមហ៊ុនការសន្ទនា)

បណ្តាញក្នុងស្រុក៖ ក្រុមអ្នកចូលរួមដែលសម្របសម្រួលដល់ការរីកចំរើនឡើងការប្រាស្រ័យទាក់ទងរបស់ក្រុមហ៊ុនជាមួយGlobal Compact នៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ (ទាំងក្រុមហ៊ុនក្នុងស្រុក និង ក្រុមហ៊ុនដែលជាសម្ព័ន្ធភាពនៃសាជីវកម្មបរទេស)

- បណ្តាញក្នុងស្រុក ជួយដល់ការអនុវត្តគោលការណ៍ទាំង១០ និងបង្កើតនូវឱកាសសម្រាប់ការប្រាស្រ័យទាក់ទងពហុភាគីនៃអ្នកពាក់ព័ន្ធ និងការធ្វើសកម្មភាពរួម ប៉ុន្តែមានការតាមឃ្លាំមើលជាប្រចាំ
- មិនមានក្រុមហ៊ុន ឬ អង្គការខាងធុរកិច្ចណាមួយ ចូលរួមក្នុងបណ្តាញក្នុងស្រុករបស់យូអិនគ្លូបលកំផែក នៅក្នុងប្រទេសកម្ពុជាទេ

កម្រិតអ្នកពាក់ព័ន្ធពហុភាគី/កម្រិតថ្នាក់ខុសរ្យាហកម្ម

- អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) នៅទីក្រុងប៉ារីស
  - គោលការណ៍ណែនាំសម្រាប់សហគ្រាសពហុជាតិ
  - ក្រុមហ៊ុនបង្គោលថ្នាក់ជាតិ (National Contact Point)
- គណៈកម្មការអន្តរ-រដ្ឋាភិបាលរបស់អាស៊ានស្តីពីសិទ្ធិមនុស្ស នៅទីក្រុងហ្សាកាតា
  - សេចក្តីប្រកាសរបស់អាស៊ានស្តីពីសិទ្ធិមនុស្ស (មិនបញ្ជាក់អំពីសហគ្រាសពាណិជ្ជកម្ម)
  - មិនមានកំណត់អំពីអណត្តិជាក់លាក់ក្នុងការទទួលបណ្តឹងបុគ្គលទេ (អនាគត?)
- ក្រុមការងារធនាគារពិភពលោក (រាប់ទាំង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ) ទីក្រុងវ៉ាស៊ីនតោនឌីស៊ី
  - ក្រុមអធិការកិច្ច និងទីប្រឹក្សាមើលលើការអនុវត្តន៍/អំបុដ្សមេន (តាមគម្រោង)
- ធនាគារអភិវឌ្ឍន៍អាស៊ី នៅទីក្រុង ម៉ានីឡា
  - យន្តការគណនេយ្យភាព (តាមគម្រោង)
- សហភាពអឺរ៉ុប នៅទីក្រុងប្រសេល
  - កតិកាសញ្ញាអឺរ៉ុប/តុលាការសិទ្ធិមនុស្សអឺរ៉ុប និង គោលនយោបាយទទួលខុសត្រូវសង្គមរបស់សាជីវកម្ម
  - គណៈកម្មការពាណិជ្ជកម្មរបស់អឺរ៉ុប

ក្រុមហ៊ុនបង្គោលថ្នាក់ជាតិនៃ OECD

- **អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍**(OECD)

  គោលការណ៍ណែនាំសម្រាប់សហគ្រាសពហុជាតិ
  - អនុសាសន៍សម្រាប់ការប្រព្រឹត្តិដោយការទទួលខុសត្រូវរបស់ធុរកិច្ច (រដ្ឋាភិបាលចំនួន ៤៤ ជាសមាជិក)
- ក្រុមហ៊ុនបង្គោលថ្នាក់ជាតិ គឺជាការិយាល័យ/ក្រុមហ៊ុន ដែលជួយដល់សហគ្រាសនានា ក្នុងការតាមសង្កេតមើលលើការអនុវត្តគោលការណ៍
  - ផ្តល់នូវវេទិកាសម្រាប់ផ្សះផ្សា និងសម្របសម្រួល សម្រាប់ដោះស្រាយបញ្ហាសាមញ្ញៗ ដែលអាចកើតមានឡើងពេលអនុវត្តគោលការណ៍ណែនាំ
- ឧទាហរណ៍នៃប្រទេសដែលជាសមាជិក OECD ដែលធ្វើវិនិយោគ ឬប្រតិបត្តិការ ឬ ផ្តល់ជំនួយអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា៖
  - អាល្លឺម៉ង់ អូស្ត្រាលី បែលហ្ស៊ិក កាណាដា កូរ៉េ ដាណឺម៉ាក អេស្ប៉ាញ សហរដ្ឋអាមេរិក ហ្វាំងឡង់ បារាំង លុចសំបួរ ជប៉ុន ហូឡង់ នរវេស្ស ញូវស្សេឡែន ចក្រភពអង់គ្លេស ស៊ុយអែត គណៈកម្មការអឺរ៉ុប

ប្រភពធនធានព័ត៌មាន និងការអានបន្ថែម

UN Guiding Principles on Business and Human Rights	http://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf
The Institute for Human Rights and Business	www.ihrb.org
OECD Guidelines for Multinational Enterprises	www.oecd.org/dataoecd/43/29/48004323.pdf
IFC Sustainability Framework	www.oecd.org/dataoecd/43/29/48004323.pdf
The Equator Principles	www.equator-principles.com
The Business and Human Rights Resource Centre	www.business-humanrights.org
The Global Compact	www.unglobalcompact.org
The Global Reporting Initiative	www.globalreporting.org
A4ID Discussion Paper on Law Firms and the Guiding Principles	http://www.a4id.org/resources/report/guidingprinciples

អរគុណ!

Appendix six: Presentation on current situation of law enforcement on land and natural resource governance

Natural Resource Governance in Cambodia: Issues and Opportunity

8th National Advocacy Conference (NAC)
2014 Theme "Working Together to Promote Effective Reform on Land and Natural Resources Governance in Cambodia"
Date: November 25th, 2014
Imperial Garden Hotel

Seak Sophat, PhD
Head, NRMD Dept., RUPP

Introduction of NRMD/RUPP

- RUPP is oldest and largest university in Cambodia, established in 1960
- Offers a wide range of undergraduate and graduate degree programs ranging from social science, humanities to natural science and engineering, including biodiversity conservation and natural resource management
- Currently it hosts nearly 20 thousand students, including scholarship and fee paying
- Dept. of NRMD established in 2012 through the successful program on environmental studies, with qualified lecturers holding PhD and Master degrees from developed countries around the world.

Introduction of NRMD/RUPP

Vision

A leading education and research institution in natural resource management, sustainable development and conservation

Mission

- To provide the best quality education and research with scientific methods and principles
- To develop practical skill and innovative knowledge to the students and interested stakeholders on natural resource management, sustainable development and conservation.

- Dept. offers Bachelor and Master programs on NRMD
- Presently, Dept. adopts the learning programs linked with research, community services, and field practices.

Our Students will learn:

- Basic theory for analyzing social and gender issues related to NRMD
- Principles of natural resource management and governance
- Management and conservation of forest and wildlife
- Analyzing climate change and sustainable energy issues
- Sustainable land resource use and Management
- Fisheries resource management
- Integrated water resource management and sustainable hydropower development.

Natural Resource Governance Issues

- High percentage of dependence on natural resources, both for economic development and rural livelihoods, as more 80% of Cambodia population live in the rural area
- Decision by RGC to conserve the natural resources is largely dependent upon the benefit to the nation as for food security and economic development
- Many of the policy and law formulations of RGC on NR may not be based on the research findings, they are developed on ad hoc basis
- The affected local communities due to the development projects had little involvement in decision making, including planning, assessment, etc.
- Many of Information and data on the development projects are not publicly available, leading to unclear comments and suggestions from NGOs, CSOs, donors community, etc.

Natural Resource Governance Issues

- There is little success to exercise and enforce the existing laws related to NRM, due to poor installed facilities, inadequate support (low salary) and little number of staff in the field.
- E.g. fisheries reform: evidence from Tonle Sap study (Phat Sanday): it is too fast for fishers to adapt to new reform, as many of them rely on Fishing lots

3

Current Research Projects of NRMD/RUPP Relevant to NR Governance

- Partnership for Environmental Action and Community Empowerment (PEACE)—Building the Space of Engagement for Environmental Governance in Cambodia, funded by ICCO, the Netherlands. January 2012- December 2014



Current Research Projects of NRMD/RUPP Relevant to NR Governance

- Harmonizing Nature and Human Society for Sustainable Development: A Symbiosis Study on the Development of Integrated Approaches for Improved Environmental Governance and Community Livelihood Strategies in Northeastern Cambodia, funded by World Bank through the Royal Government of Cambodia's Ministry of Education Youth and Sports. Jan 2013-Dec 2014

Current Research Projects of NRMD/RUPP Relevant to NR Governance

- Community based conservation and monitoring of globally endangered bird biodiversity in Sekong and Sesan River IBA sites in Stung Treng and Ratanakiri provinces, Cambodia. January 2013 to December 2015, funded by MacArthur Foundation
- Water-related Risks of Rural Livelihood and Biodiversity: An Assessment of Transboundary Impacts Caused by Flow Changes in 3S River Basin under Dam Development and Climate Change, funded by UNESCO-IHE, the Netherlands. Jan 2013 to Dec 2014



Current Research Projects of NRMD/RUPP Relevant to NR Governance

- Aquatic and Agricultural System in Tonle Sap Lake, partner with WorldFish Center, 2013-2017

- Strengthening Community Based Bird Biodiversity Conservation and Monitoring Through Local Livelihood Improvement and Capacity Building in 3S River Basin, Cambodia, funded by Critical Ecosystem Partnership Fund (CEPF). Oct 2014 to Sep 2017

5

Opportunity on NRM and Governance

- Improve the enforcement of existing law and regulations
- Improve the data and information exchange among the relevant stakeholders
- Encourage the private sector and others to involve in the NRM and development
- Provide sufficient support and facility to govt. officials to exercise their duty in the field
- Enhance the capacity building for relevant stakeholders, particularly NR managers
- Enhance the academic involvement in NR governance, especially research, training and providing community services
- Integrate NRM into sub-national development planning, and govt. financing
- Strengthen cooperation among the relevant stakeholders, especially govt., local community, NGOs, private sector, and academics
- Policy and law formulation for long term NRM should be based on research findings

Conclusion remarks

- NR is a backbone of Cambodia economy, and livelihood of 80% of her population
- Current hot issues of NR: land concession, hydropower building, mining, illegal logging (especially luxury timber for export to foreign countries)
- Appropriate management systems: co-management, community based approach
- Siting appropriate locations for land concession, mining, hydropower; and promoting participatory action (respect rights of local community to be affected)
- Conservation for betterment of livelihood of local community such as REDD+ initiatives
- Law enforcement, increase support to govt. officers in charge of NRM, fighting corruption

Thank you for your attention

7